ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ: ១២៦៥ / ប.ស.ស
១៦

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧ ឆ្នាំ២០១៦

# សេចក្តីណែនាំ

## ស្តីពីការកែសម្រួលនីតិវិធី និងបែបបទនៃការផ្តល់របាយការណ៍កម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់សហគ្រាស គ្រឹះស្ថាន ដែលបានកំណត់កាតព្វកិច្ចក្នុងរបបថែទាំសុខភាព

អនុលោមតាមប្រកាសលេខ ២៨៥ ក.ប/ប្រ.ក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ ៣, ប្រការ ៤ និងប្រការ ៥ នៃប្រកាសលេខ ០២១ ក.ប/ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានកិត្តិយស សូមធ្វើការណែនាំដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីនីតិវិធីនិងបែបបទនៃការផ្តល់របាយការណ៍កម្មករនិយោជិត ដូចខាងក្រោម ៖

១- ជារៀងរាល់ខែនិយោជកឬម្ចាស់សហគ្រាសគ្រឹះស្ថានត្រូវធ្វើរបាយការណ៍អំពីចំនួនកម្មករនិយោជិតដែលបានប្រើប្រាស់ទាំងអស់មកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់

២- ចំពោះកម្មករនិយោជិតដែលទើបចូលបំរើការងារថ្មី ហើយមិនទាន់មានលេខអត្តសញ្ញាណ ប.ស.ស (លេខ ១៥ខ្ទង់) និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចបញ្ជូនកម្មករនិយោជិតថ្មីនេះ មកចុះបញ្ជិកានៅ ប.ស.ស តាមទម្រង់សលាកប័ត្រព័ត៌មាន យ៉ាងយូររយៈពេល ០៣ថ្ងៃ បន្ទាប់ពីអនុញ្ញាតឲ្យចូលធ្វើការ ដើម្បីទទួលបានលេខអត្តសញ្ញាណ ប.ស.ស (លេខ ១៥ខ្ទង់)

៣- សេចក្តីណែនាំលេខ៣៧៤/១៦ប.ស.ស ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៦ត្រូវចាត់ទុកជានិរាករណ៍។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមេត្តាជ្រាប និងត្រូវមានកាតព្វកិច្ចអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក_សមវិទ្យា**

*កន្លែងទទួល*

- *ថ្នាក់ដឹកនាំប.ស.ស*
- *គ្រប់ការិយាល័យប.ស.សថ្នាក់កណ្តាល*
- *គ្រប់សាខា ប.ស.សរាជធានី/ខេត្ត*
- *គ្រប់សហគ្រាស គ្រឹះស្ថាន (សហការអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៨៨ ១០ ១៥ ០២៣-៨៨ ១០ ១៦ , ០២៣ ៨៨ ០៤ ១៧
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh